# ការសម្ភាសរបស់ សន សំ

ក៖ អ្នកសម្ភាសឈ្មោះ កុយ សុភី ខ៖ អ្នកត្រូវបានគេសម្ភាស សន សំ

*<u>ការសង្ខេបប្រវត្តិរបស់ សន សំ</u>*

*ការសម្ភាសនៅឆ្នាំ២០១៨ លោកយាយ សន សំ មានអាយុ៧២ឆ្នាំ កើតនៅឆ្នាំកោរ នៅក្នុងភូមិព្រៃកអណ្តូង ឃុំព្រៃកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម។ លោកយាយមានបងប្អូន ៣នាក់ លោកយាយកូនពៅគេនៅក្នុងគ្រួសារ ក្រោយមកលោកយាយបានមានគ្រួសារដោយសារឪពុកម្តាយជាអ្នករៀបចំទុកដាក់ឱ្យ ដោយអត់មានបានចូលរៀនសូត្រនោះទេ ព្រោះខ្លាចចេះសរសេរសំបុត្រស្នេហា ក្រោយមកចូលនៅក្នុងរបបលន់នល់ ជីវិតយាយលំបាកមែនទែន ព្រោះត្រូវមានកូនហើយឆ្លងទន្លេនោះក្នុងរបបនោះ។ គេប្រើឱ្យរែកជីស្ទូងស្រូវជាដើម រហូតបានដាច់ជំនាន់ប៉ុលពត លោកយាយ និង ស្វាមីបានរកស៊ីលក់បន្លែ ដាំបន្លែដើម្បីចិញ្ចឹមគ្រួសារ ។ មកដល់ឥឡូវលោកយាយចាស់ហើយនៅផ្ទះ បានកូនជួយចិញ្ចឹម។*

ក៖ ចាសជម្រាបសួរយាយ សព្វថ្ងៃនេះយាយសុខសប្បាយទេយាយ?

ខ៖ សុខសប្បាយទេ!

ក៖ ខ្ញុំឈ្មោះ កុយសុភីបានមកធ្វើការសម្ភាសយាយនៅឆ្នាំចរ សំរិទ្ធស័កពុទ្ធសារាជ ២៥៦២ ខែមិគសិរ ៨កើត ត្រូវនឹងថ្ងៃសៅរ៍ ទី១៥ ខែធ្នូ ឆ្នាំ២០១៨។ នាមត្រកូលយាយឈ្មោះអ្វី?

ខ៖ សន សំ!

ក៖ សនសំ?

ខ៖ ចាស!

កៈ ឈ្មោះហ្នឹងអ្នកណាជាអ្នកដាក់ឈ្មោះអោយយាយ?

ខៈ ម្ដាយ!

កៈ ម្ដាយ?

ខៈ ចាស!

កៈ ចាស! តើឈ្មោះហ្នឹងមានអត្ថន័យយ៉ាងដូចម្ដេចដែរ?

ខៈ អត្ថន័យម៉េច?

កៈ អត់ដឹងនោះទេយាយ?

ខៈ ហ្នឹងហើយ!

កៈ ចាស! តើមានឈ្មោះហៅក្រៅ១ទៀតដេស?

ខៈ អត់មានផង។

កៈ ចាស!

ខៈ ចាស!

កៈ ចុះយាយសញ្ជាតិអ្វី?

ខៈ សញ្ជាតិខ្មែរ។

កៈ ចាស! យាយកើតនៅថ្ងៃខែឆ្នាំណា?

ខៈ អឹមមិនចាំនោះទេខ្ញុំ។

កៈ ចាស! ចុះឆ្នាំខ្មែរតើឆ្នាំអ្វី?

ខ៖ វាមិនចាំណុងណាវាយូរហើយ ឆ្នាំកោរ។

ក៖ឆ្នាំកោរ

ខ៖ ចាស!

ក៖ ហើយមកដល់ពេលឥឡូវនេះយាយមានអាយុប៉ុន្មានហើយ?

ខ៖ ៧២!

ក៖ ចាស! ៧២ យាយមានទីកន្លែងកំណើតនៅក្នុងភូមិ ឃុំ ?

ខ៖ ភូមិហ្នឹង។

ក៖នៅភូមិព្រៃកអណ្ដូងហ្នឹងហេសយាយ?

ខ៖ ចាសៗ!

ក៖ ចឹងនៅឃុំព្រៃកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម។

ខ៖ កំពង់ចាម!

ក៖ ចឹងហេសយាយនេស នាមត្រកូលឪពុកយាយណា ឈ្មោះអ្វី?

ខ៖ តាសន ហ្នឹងហើយ។

ក៖ តាសន!

ខ៖ អឺ!

ក៖ ចុះនាមត្រកូលរបស់គាត់ដាក់អីគេសន?

ខ៖ ហែម!

កៈ ហែម សន ចឹងហេសយាយណា?

ខៈ ចាស!

កៈ ចាសអីគាត់សព្វថ្ងៃគាត់នៅរស់ហេស?

ខៈ ខូចអស់ហើយ!

កៈ កាលគាត់ស្លាប់នុងនៅអាយុប៉ុន្មាន?

ខៈ ស្លាប់នៅអាយុតាំងពី៥០ម៉េស

កៈ ៥០! តើគាត់ស្លាប់ដោយសារមូលហេតុអ្វី?

ខៈ ឈឺ!

កៈ ជម្ងឺ!

ខៈ ចាស!

កៈ តើគាត់បានចូលរៀនដេសយាយ?

ខៈ គាត់រៀន!

កៈ គាត់រៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែរ?

ខៈ រៀនមិនដឹងថាត្រឹមថ្នាក់ទីប៉ុន្មាននោះទេ កាលណុងខ្ញុំនៅតូចដែរ។

កៈ ចឹង!

ខៈ ចាស!

កៈ ចុះដឹងថាគាត់មានអត្តចរិតយ៉ាងម៉េចដែរយាយ?

ខ៖ គាត់មានអី គាត់ល្អតើ។

ក៖ ចឹងគាត់មានមុខរបរ?

ខ៖ មុខរបរកាលណុងដាំថ្នាំ។

ក៖ ចឹងដាំតែថ្នាំមួយមុខនោះទេយាយ?

ខ៖ ដាំតែថ្នាំហើយនិងត្រសក់។

ក៖ ចឹងដាំត្រសក់ដែរ។

ខ៖ ចាស!

ក៖ ត្រសក់ផ្អែយើងហ្នឹងយាយ?

ខ៖ ត្រសក់ផ្អែ!

ក៖គាត់មានមូលកំណើតគាត់កើតនៅភូមិ?

ខ៖ នៅភូមិហ្នឹង។

ក៖ ចឹងភូមិហ្នឹងដែរ?

ខ៖ ចាស!

ក៖ ចាស! តើបងប្អូនបង្កើតៗដូចជាបងទី១ឈ្មោះអ្វី?

ខ៖ ឈ្មោះ តាគល់។

ក៖ ភេទប្រុសណាតា?

ខ៖ ចាស!

កៈ ហើយចុះមកទី២?

ខៈ តាបាវ!

កៈ ទី៣!

ខៈ យាយសៀម ស្រី។

កៈ ចាស! សៀមចឹងហ៎?

ខៈ ចាសស្រី!

កៈ ហើយទៅទៀតយាយ?

ខៈ ហើយបានតាសនហ្នឹងគាត់កូនពៅគេ។

កៈ អូ!

ខៈ បងប្អូនគាត់៩នាក់។

កៈ ចាសៗ! ចុះនាមត្រកូលម្តាយយាយវិញឈ្មោះអ្វី?

ខៈ យាយស័ន!

កៈ ចឹងដាក់នាមត្រកូលគាត់ផង។

ខៈ ជា!

កៈ ជាស័ន?

ខៈ ចាស!

កៈ គាត់សព្វថ្ងៃគាត់នៅរស់ហោស?

ខ៖ ខូចអស់ហើយ។

ក៖ ខូចនៅអាយុប៉ុន្មានដែរយាយ?

ខ៖ គាត់ខូចតាំងពី៨៣ម៉េច។

ក៖ គាត់អាយុ៨៣បានស្លាប់?

ខ៖ ចាស!

ក៖ ចុះគាត់ស្លាប់ដោយសារតែមូលហេតុអ្វី?

ខ៖ ឈឺដែរ។

ក៖ ចុះគាត់បានសិក្សាបានត្រឹមថ្នាក់ទីប៉ុន្មាន?

ខ៖ អូ! គាត់អត់ចេះនោះទេ។

ក៖ គាត់អត់ចេះអក្សរតែម្តង?

ខ៖ ចាស!

ក៖ ចឹងគាត់មានអត្តចរិតយ៉ាងម៉េចដែរ?

ខ៖ មានអីគាត់ស្លូតបូតដែរ!

ក៖ អូ! គាត់មានមុខរបរអ្វី?

ខ៖ មុខរបរគាត់ធ្វើថ្នាំហើយនិងពោតហ្នឹង

ក៖ ជាមួយគ្នា?

ខ៖ ជាមួយគ្នាណុង។

កៈ ទីកន្លែងគាត់កើត?

ខៈ គាត់កើតនៅត្រើយម្ខាង។

កៈ ចុះមានចាំដែរឬទេថាគេហៅថានៅក្នុងភូមិអ្វី?

ខៈ នៅក្នុងស្វាសាច់ភ្នំ។

កៈ ស្វាសាច់ភ្នំ?

ខៈ ចាស!

កៈ ឃុំ?

ខៈ ឃុំអីនោះទេ ភ្លេចហើយ។

កៈ ស្រុកកងមាសយើងដែរហេសយាយ?

ខៈ កងមាសយើងដែរ។

កៈ ចឹងនៅក្នុងខេត្តកំពង់ចាមយើងដែរយាយ?

ខៈ អឺ ខេត្តកំពង់ចាម។

កៈ ចឹងយាយមានគាត់ដំណាលប្រាប់ដែរថា តើមានមូលហេតុអ្វីបានជាគាត់មកដណ្ដឹងគាត់ដូចថានៅឆ្ងាយភូមិខុសភូមិគ្នាចឹងណា?

ខៈ នៅឆ្ងាយក៏ប៉ុន្តែជីដូន១។

កៈ អូ! ជាប់សាច់ឈាម។

ខៈ ចាស! ហើយក៏ភ្ជាប់គ្នាទៅ។

កៈ ចាសចឹងនេស។ ចាស! តើបងប្អូនបង្កើតរបស់ម្ដាយយាយណា។

ខៈ ៨ទៅ៩នាក់ខូចអស់រលីង អត់មាននៅសល់មួយនោះទេ។

កៈ ចុះយាយមានបានចាំបងគាត់ទី១ បងរបស់គាត់?

ខៈ បងទី១ តាណាង។

កៈ តាណាង!

ខៈ តាណាង១ យាយសាំង១។ ចាសរួច តានង តានាង តាឡុង យាយស័ន ទាំងអស់៨នាក់បងប្អូនគាត់។

កៈ ទើបបាន៦។

ខៈ យាយសាំង។ ចាស!

កៈ ចឹងអ្នកណាម្នាក់ទៀត?

ខៈ តាណាងនៅឯនុងដែរ

កៈ ចាស!

ខៈ បងប្អូនរបស់គាត់៨នាក់ខូចទាំងអស់ហើយមានអីអស់។

កៈ យាយបានរៀបអាពាហ៍ពិពាហ៍នៅក្នុងសង្គមអ្វី? ហៅសង្គមអីគេកាលណុង?

ខៈ សង្គមរាស្ត្រជានិយម។

កៈ ចាស! សម្ដេចឪយើងយាយនេស?

ខៈ ចាស! ជំនាន់សម្ដេចឪ។

កៈ កាលណុងយាយបានបង្គាប់ថ្លៃទឹកដោះបានប៉ុន្មាន?

ខៈ បានប៉ុន្មាននោះទេ បាន៤តុ។

កៈ បាន៤តុហ្នំ។

ខៈ ហាសៗ៤ស្តក ស្តកគេស៊ីនៅដីនោះ។

កៈ ចឹង!

ខៈ អើ!

កៈ ចឹងកាលណុងជំនាន់ស្តក បាន៤តុ។

ខៈ បាន៤ស្តកមិនមែនតុនោះទេ

កៈ អូចឹង៤ស្តក គេជូនស្តកចឹងតែម្តង?

ខៈ ស្តកនុណុងគេស៊ីស្តកណុងណា។

កៈ ហើយម៉ាស្តកណុងប៉ុន្មាននាក់?

ខៈ ម៉ាស្តកណុងចេះតែនាំគ្នាស៊ីទៅ ដូចតែយើងនេះទៅដែរ មិនបានរាប់មនុស្សអីឯណា។

កៈ ហើយចុះម្ហូបគេដាក់យ៉ាងម៉េចដែរទៅយាយ?

ខៈ ម្ហូបគេស្លឃ្លោកទៅ គេស្លអីចឹងណាហាសៗ។

កៈ អូ!

ខៈ កាលណុងមានស្លអី។

កៈ ចុះកាលណុងមានអីកំដររោងអីដេស កុំឱ្យស្ងាត់គេមានលេងកេសអីដែរ?

ខ៖ វាគ្មាននោះ កាលពីដើមគ្មាននោះទេ មានតែស្គរដៃ។

ក៖ ចឹងមានស្គរដៃណុងនោះទេ។

ខ៖ ស្គមដៃៗហាសៗ។

ក៖ រាំទៅយាយ។

ខ៖ រាំទៅហើយនឹងផុងសាំង។

ក៖ អូស! ចឹងកាលណុងរាំលក់ទាល់តែភ្លឺទៅយាយ?

ខ៖ ហាសៗណុងហើយ។

ក៖ អូ! សប្បាយដែរ តើយាយការណុង តើយាយការនៅអាយុប៉ុន្មានដែរ?

ខ៖ នៅអាយុ១៨។

ក៖ ១៨កំពង់តែពេញស្អាត ចុះយាយមានបានចូលសិក្សាដេសយាយ?

ខ៖ អត់គាត់ អត់មានបានចូលរៀន!

ក៖ អត់បានរៀនសោះ?

ខ៖ អត់!

ក៖ មូលហេតុអ្វីបាន...

ខ៖ គាត់មិនបានឱ្យព្រោះគាត់ថាចែក ឪពុករបស់ខ្ញុំគាត់ថាមិនឱ្យរៀនណុងខ្លាចសរសេរអក្សរ។

ក៖ ចេះសរសេរសំបុត្រស្នេហាអីចឹងហោស?

ខ៖ ចាស! ហាសៗ។

ក៖ អូចឹងស្រីអត់ឱ្យរៀនតែម្តង?

ខ៖ អត់ឱ្យរៀនទេ។

ក៖ អូ! រួចទៅបានយាយអត់ចេះអក្សរផង ចឹងយាយកាន់សាសនាអ្វី?

ខ៖ កាន់សាសនាយើងហ្នឹង។

ក៖ តើយាយមានមុខរបរធ្វើអ្វីដែរ?

ខ៖ មុខរបរពីដើមធ្វើតែនេះណុង ធ្វើតែថ្នាំ ធ្វើតែអីគគោកណុង ធ្វើតែស្រូវណុង។

ក៖ ចាស! ចឹងបងប្អូនរបស់យាយមានប៉ុន្មាននាក់?

ខ៖ មាន៣។

ក៖ ៣នាក់ហ្នូ៎?

ខ៖ ៣!

ក៖ ចាស! ទី១ឈ្មោះអ្វី?

ខ៖ សន តេង!

ក៖ សនតេងភេទ?

ខ៖ ភេទប្រុស!

ក៖ ចាស! ទី២?

ខ៖ សនតុង។

កៈភេទ?

ខៈ ភេទប្រុសដែរ។

កៈ ហើយដល់យាយកូនពៅគេ?

ខៈ ចាស!

កៈ អូ! រួចទៅអឺ យាយដូចថាប្ដីលោកយាយដូចថាគាត់ឈ្មោះអ្វី?

ខៈ វ៉ែន រឿន។

កៈ វ៉ែនរឿនហោស?

ខៈ ចាស!

កៈ ចាស! គាត់កើតនៅថ្ងៃខែឆ្នាំណា?

ខៈ មិនដឹងឆ្នាំណានោះទេ ខ្ញុំមិនបានសួរគាត់ព្រោះគាត់ងាប់អស់ទៅហើយនោះ។

កៈ កាលគាត់ស្លាប់នុងនៅអាយុប៉ុន្មាន?

ខៈ អាយុ៦៧!

កៈ តើគាត់ស្លាប់ដោយសារមូលហេតុអ្វី?

ខៈ ឈឺ!

កៈ ឈឺជម្ងឺបាំ?

ខៈ ចាស!

កៈ ចាស! ហើយតើគាត់បានសិក្សាដេស?

ខ៖ បាន!

ក៖ អូ! គាត់ចេះភាសាបរទេសដែរណេង?

ខ៖ អត់ទេ! មិនចេះនោះទេបរទេសនោះ។

ក៖ ចុះអត្តចរិតរបស់គាត់យ៉ាងម៉េចដែរ?

ខ៖ មានអីគាត់ល្អ។

ក៖ ចាស! ទីកន្លែងគាត់កើតនៅ?

ខ៖ នៅហ្នឹង។

ក៖ នៅហ្នឹងដែរហ្ន៎។

ខ៖ នៅក្រោយនេះផ្ទះគាត់។

ក៖ ចាស! បងប្អូនបង្កើតខាងស្វាមីយាយទី១ឈ្មោះ?

ខ៖ យាយ តឹប។

ក៖ យាយ តឹបភេទ?

ខ៖ ភេទស្រី។

ក៖ ដាក់ត្រកូលឱ្យគាត់ផងយាយ។

ខ៖ ដាក់ត្រកូលហ្នឹងហើយ សន។

ក៖ ចឹងមកទី២?

ខ៖ ឆៀង!

កៈ ភេទប្រុសហ្នឹ ចុះទី៣?

ខៈ ហ៊ឹមទី៣ សុខឃាន់ភេទស្រី ទី៤ញ៉ ភេទស្រីដែរ ហើយអាឃួយនោះងាប់បាត់ទៅហើយ។

កៈ ចាស! យាយមានកូនចំនួនប៉ុន្មាននាក់?

ខៈ ៦តែខូច១ហើយ។

កៈ កូនទី១ឈ្មោះ?

ខៈ រស់ហ្នឹង។

កៈ អ្វីរស់?

ខៈ រឿន រស់!

កៈ រឿន រស់?

ខៈ ចាស!

កៈ ភេទប្រុសនេស?

ខៈ ចាស!

កៈ ទី២?

ខៈ ទី២ រឿន រឿង

កៈ រឿង!

ខៈ ហ្នឹងខូចហើយ។

កៈ ខូចហើយចុះទី៣?

ខ៖ ទី៣សឿន។

ក៖ រឿន សឿន!

ខ៖ ចាស! ស្រី!

ក៖ ទី៤?

ខ៖ ទី៤ រ៉េត

ក៖ រឿន រ៉េត

ខ៖ ភេទប្រុស។

ក៖ ទី៥?

ខ៖ ទី៦ស៊ីម!

ក៖ រឿនស៊ីម ចឹងអស់ហើយហេសយាយ?

ខ៖ ៦! មើលនៅម៉ាប១ទៀត

ក៖ ចាស! រឿនម៉ាបចឹងហេស?

ខ៖ ចាស!

ក៖ ចឹងត្រូវហើយ៦ណាយាយ?

ខ៖ ចាស!

ក៖ ចាស! ហើយទៅសព្វថ្ងៃយាយមានចៅចំនួនប៉ុន្មាន?

ខ៖ ចៅច្រើនណាស់។

ក៖ ចៅច្រើនហ៊ឹម។

ខ៖ ម្នាក់៥ ម្នាក់៣ ម្នាក់៤។

ក៖ ហ៊ឹម! យាយមានចៅចំនួន២០នាក់ចឹងនេសយាយ?

ខ៖ ចាស!

ក៖ ស្រី?

ខ៖ ស្រី៧

ក៖ ចាស! ស្រី៧នាក់ណាយាយ?

ខ៖ ចាស!

ក៖ យាយមានចៅទួត?

ខ៖ ចៅទួត៣!

ក៖ ចៅទួត៣នាក់ទៀតហើយ មកដល់ពេលឥឡូវយាយមានអាយុច្រើនដែរ ក៏ប៉ុន្តែយើងដឹងអំពីជីតា ជីដូនអីដែរដំណាលប្រាប់យាយពីកាលដែលគាត់រស់នៅមុនៗហ្នឹងអី តើមាននិយាយប្រាប់យាយថាយ៉ាងម៉េចខ្លះ ?

ខ៖ ធ្វើល្អីអីណុងណា ធ្វើល្អីដូរស្រូវ។

ក៖ ជីវភាពរបស់គាត់ណុង?

ខ៖ ជីវភាពគាត់ធ្វើល្អីដូរស្រូវមកចឹង។

ក៖ ចាស!

ខ៖ ធ្វើល្អីធ្វើអីចឹងទៅដូរស្រូវទៅ។

ក៖ អូ!

ខ៖ ចាស! កាលពីដើមមកនោះ គាត់មានបានទៅធ្វើអីនោះទេ។ ចាស់ៗហើយនោះ ហើយជីដូនរបស់ខ្ញុំកាលពីដើមគាត់ត្បាញហូល។

ក៖ អូចឹងនៅយើងហ្នឹងកាលពីដើមចេះត្បាញហូរដែរ?

ខ៖ ចេះទេ!

ក៖ ចឹងត្បាញហូរទៅ តាគាត់ធ្វើល្អីទៅ។

ខ៖ ចាស! ហើយតាគាត់ធ្វើល្អីទៅ ហើយអាហូរនោះធ្វើទៅគេលួចអស់ ហាសៗ។

ក៖ ហ៊ឹម!

ខ៖ គេលួចអស់១គីទៅ

ក៖ ចាស!

ខ៖ កាលពីដើមនោះ ហើយមកដល់ចៅៗកូនៗគ្មានពីណាគេចេះនោះទេ។

ក៖ ចេះនោះទេឥឡូវក្មេងនៅសម័យឥឡូវ ចឹងបានចង់ដឹងថាយាយ ពីដើមចេះធ្វើអីខ្លះចឹងណា?

ខ៖ ចេះធ្វើអី!

ក៖ ចឹងតើគាត់បានដំណាលប្រាប់ថាយ៉ាងម៉េចទៀតយាយ?

ខ៖ គាត់គ្រាន់តែថាចៅអើយ កូនអើយឱ្យខំរកស៊ីទៅណា។ កុំឱ្យពិបាកមានកូនមានចៅកុំឱ្យពិបាក។

កៈ ចឹងហ្អ៎!

ខៈ ចាស!

កៈ យាយបានឆ្លងកាត់នៅក្នុងរបរសង្គមណាខ្លះយាយ?

ខៈ ខ្ញុំសង្គមតាំងពីខ្ញុំដឹងក្ដីមក តាំងពីខ្ញុំពីបារាំងហ្នឹង។

កៈ ជំនាន់បារាំង។

ខៈ ជំនាន់បារាំងព្រៃទទឹងហ្នឹង

កៈចាស!

ខៈ ចាស!

កៈ ចឹងជំនាន់បារាំងហ្នឹង តើឱ្យប្រជាជន ខ្មែរយើងហ្នឹងមានជីវភាពយ៉ាងម៉េចដែរនៅកាលណុង?

ខៈ មានអីជីវភាពនៅពេលណុង គេឱ្យទៅធ្វើអង្កអីបារាំងហ្នឹង មករកយាយហ្នឹងម្ដាយក្មេកខ្ញុំរែងអង្កបារាំងហ្នឹង។

កៈ ចឹងបារាំងវាជួលយើងឱ្យទៅរែងអង្កហេស?

ខៈ ចាស!

កៈ អូចាស!

ខៈ ហើយខ្ញុំជីវភាពគ្រាន់តែបះគ្រក្ងួនអីយកទៅលក់ហ្នឹងមានអីទេ។

កៈ ចឹង!

ខ៖ មានតែជីវភាពគ្រកួន ស្បៀ មានតែរកខ្ទង់អីលក់ហ្នឹងមានអី។

ក៖ ចឹងជីវភាពហ្នឹងយកមកចិញ្ចឹមគ្រួសាររស់ដែរយាយ?

ខ៖ រស់ទាល់តែសព្វថ្ងៃហ្នឹង។

ក៖ ចាស! រស់ចឹងរស់ដោយ។

ខ៖ ដោយទាំងស្រដរ។

ក៖ ចាស! វាមិនសល់ មានអីចឹងណា។

ខ៖ ហ្នឹងហើយមិនទេ គ្មានសល់នោះទេ។

ក៖ រួចរហូតធ្វើជីវភាពហ្នឹងរហូតទៅអត់មានផ្លាស់ប្តូរមុខរបបអីទៀតនោះទេយាយ?

ខ៖ ផ្លាស់ប្តូរមករហូតហ្នឹង បានមកយើងធ្វើដី ធ្វើអីខ្លះទៅណា ធ្វើស្រែធ្វើស្រូវអីខ្លះចឹងទៅណា។

ក៖ ចឹងហ្អ៎?

ខ៖ ចាស!

ក៖ ហើយដល់ពេលជំនាន់បារាំងមក តើមានជំនាន់អ្វីគេទៀតយាយមានចាំដែរឬទេ?

ខ៖ អឺម! មិនសូវចាំដែរនៅកាលណុងគ្រាន់តែដឹងថាម៉ាខ្ញុំគាត់ថា កាលជំនាន់ឥស្សរៈអីហ្នឹងណា។

ក៖ ឥសិរៈនុងយ៉ាងម៉េចដែរយាយ?

ខ៖ ឥស្សរណុង ឈឺម ពួកឈឹមវាយគ្នាហ្នឹងណាថាម៉េច ឈឹមស្រុក ឈឹមព្រៃណុងណា គាត់និយាយណា។

កៈ ខ្ញុំអត់យល់ដែរ ថាម៉េចឈឹមស្រុកឈឹមព្រៃ?

ខៈ ហាក់! ហ្នឹងកាលពីដើមមក កាប់ចាក់គ្នាឥស្សរនោះ។

កៈ វាយកាប់ចាក់ចឹងហេសយាយ។

ខៈ ចាស! កាលណុងគាត់ថា នេះគាត់បាននិយាយកាលពីដើមនោះទេណា។

កៈ ចាស!

ខៈ គាត់ថារត់សុតតែចង់ ឥស្សរហ្នឹងរត់ចង់អង្គង់ជើងហ្នំ។ ចាស! បើសិនជាគ្នាអង្គង់នោះទេ នោះមិនមែនទេ។ ចាស! កាលនុងហ្នំ។

កៈ ចឹងគាត់សម្គាល់ចឹងហេសយាយ ចង់អង្គង់ជើង។

ខៈ អើ! កាលណុងជំនាន់ដើម។

កៈ អាហ្នឹងពួកឥស្សរចាប់ទៅហើយចឹងហេស?

ខៈ ចាស!

កៈអូ! រួចទៅបន្ទាប់មកទៀត យាយឆ្លងកាត់នៅរបបប៉ុលពត?

ខៈ ចាស! មករបបប៉ុលពត។

កៈ ចាស! នៅរបបប៉ុលពតណុង តើយាយអីរបបណុង តើគេឱ្យយាយធ្វើការងារយ៉ាងម៉េចអ្វីខ្លះ?

ខៈ វែកដី។

កៈ វែកដី។

ខ៖ ជាមួយតាស៊ីលណុង។

ក៖ កាលណុងយាយអាយុប៉ុន្មានដែរនៅក្នុងរបបប៉ុលពតណុង?

ខ៖ ហ៊ឹម! របបប៉ុលពតណុងអាយុ៥០ជាងហើយ។

ក៖ ចឹងបានវែកដីទៀត?

ខ៖ វែកដី!

ក៖ ហ៊ឹម!

ខ៖ អាយុប្រហែលជា៥០ទៅ៦០ណុង។

ក៖ ចាស!

ខ៖ ចាស

ក៖ ហ៊ឹម!

ខ៖ វែកដីនៅចំកែងទួយនុង វែកដីកាប់ព្រៃបាយនៅឯណុង មិនដឹងយប់ទេអីគេស្នូងស្រូវយប់។

ក៖ អូចឹងគេស្នូងស្រូវយប់?

ខ៖ យប់ណា!

ក៖ ស្នូងយប់មើលឃើញ?

ខ៖ បើខែភ្លឺហ្នំ។

ក៖ អូ! ស្នូងយប់ហើយខែភ្លឺហោសយាយ?

ខ៖ ហ្នឹងហើយ មិនមែនខ្ញុំចេះតែថានោះទេយប់។

ក៖  ចាស!  អូ!  ចុះគេឱ្យយាយរែកដីនៅកាលជំនាន់ណុងដូចថាណុងរែកបានប៉ុន្មានម៉ែត្រនៅក្នុង១ម៉ែត្រ?

ខ៖ ៣!

ក៖ ៣ម៉ែត្រ រែករួចហេសយាយ?

ខ៖ រែករួចផ្សំទៅ ហើយប្រធានកងណុងគេជួយខ្លះអីខ្លះចឹងទៅណា

ក៖ ចាស! អូយាយ ៣ម៉ែត្រហ្នំ។

ខ៖ ១ថ្ងៃ៣ម៉ែត្រ។

ក៖ យាយរែកនៅកន្លែងណា?

ខ៖ រែកនៅខាងចំកែងទួយនៅចម្ការឪឡឹក។

ក៖ ចឹងទៅទំនប់តាកុតយើងហ្នឹង?

ខ៖ នៅខាងនេះ។

ក៖ តាកុតចឹងហេស។

ខ៖ អត់ដល់តាកុតនោះទេ តាកុតពួកអ្នកថ្មី។

ក៖ ចឹងហ្នំអូ!

ខ៖ នៅចម្ការឪឡឹក។

ក៖ ខាងចម្ការឪឡឹក។

ខ៖ ចម្ការឪឡឹកអាប្រាក់ថ្មីហ្នឹង។

ក៖ ចាស! ដល់ពេលរួចពីរែកដីតើគេឱ្យយាយ។

ខ៖ កាប់ព្រៃ!

ក៖ កាប់ព្រៃ!

ខ៖ កាប់ព្រៃហើយស្ទូង។

ក៖ ស្ទូងទៀត!

ខ៖ ចាស!

ក៖ ចេះតែធ្វើការនុងចេះតែទៅរួចហើយយាយ?

ខ៖ ចេះតែទៅហើយព្រោះអីខ្លាចងាប់។

ក៖ ហ៊ឹម! អត់ដែរ។ យាយមានឈឺអីដេស?

ខ៖ អត់ទេ! កាលណុង។

ក៖ ចេះតែមានកម្លាំងទៅ។

ខ៖ រួចមក ខ្ញុំមានកូនអាឆ្នាំមមីណុង ជិតគ្រប់ខែគេមិនឱ្យឈប់ទៀតហ្អ៎។

ក៖ ជំនាន់ប៉ុលពតណុងហើយ?

ខ៖ ហ្នឹងហើយ!

ក៖ អូ!

ខ៖ គេឱ្យយើងស្ទូងទាំងពោះធំណុងណា។

ក៖ ចឹងកើតនៅស្ទូងណុងចឹង?

ខ៖ ពេលណុងហ្នឹងណា ដល់ពេលចូលគ្រាប់ខែហ្នឹងគេឱ្យនៅរោងបាយ។

ក៖ ឱ្យនៅរោងបាយវិញ?

ខ៖ ចាស! ឱ្យនៅរោងបាយ៣ថ្ងៃណុង។

ក៖ កើតកូន!

ខ៖ ហ្នឹងហើយ វេទនាចឹងណា។

ក៖ ហ៊ឹម! ចាស! កើតហើយបានប៉ុន្មានថ្ងៃដែរយាយបានគេឱ្យយើងទៅធ្វើការអីទៀត?

ខ៖ កើតបានកន្លះខែ!កន្លះខែនុងដាច់ទៅ។

ក៖ អូចាស ចេះបានដាច់យាយអើយ កុំអីទៅធ្វើការទៀត។ ចាស! ចឹងហើយថានៅក្នុងរបប ណុង គេអត់ឱ្យយើងហូបអីគ្រាប់គ្រាន់នោះទេយាយ?

ខ៖ ទេ! គេមិនឱ្យនោះទេ។

ក៖ ប៉ុន្តែយាយចេះតែមានកម្លាំងទៅណាយាយនេស ចេះតែធ្វើទៅ។

ខ៖ បបរ១វែក ហើយស្រងមកអង្កមិនបាន១វែកផងយកមកឱ្យកូនណុង សម្រិតហូបតែទឹក នោះទេ កាកឱ្យកូន។

ក៖ កូននៅតូចៗ។

ខ៖ កូននៅតូច។

ក៖ កាលណុងកូននៅតូចជាប់នឹងខ្លួនយាយហ្នឹង?

ខ៖ គ្មាននៅនឹងខ្លួននោះទេ គេនៅមន្ទីរកុមារឯនោះ។

កៈ គេឱ្យនៅមន្ទីរកុមារ។

ខៈ ចាស!

កៈ ចឹងអ្នកមើលកុមារផ្សេងដែរចឹង?

ខៈ ចាស! ធ្វើៗណុងដូចថាអាហ្នឹង អាមួយហ្នឹងដែលថាខូចទៅណុង គេឱ្យទៅចល័ត នៅលើអាចម៍គោនោះ។

កៈ ចាស!

ខៈ ទៅរៀនលើកអាចម៍គោនោះ។ ហឹសៗ!

កៈ ហឹសដល់ពេលល្ងាចឡើងបានមកជុំគ្នា?

ខៈគេមិនឱ្យមើលតើ។

កៈ ចឹងអត់មានមកជុំម្ដាយអីនោះទេ?

ខៈ អត់ទេ។ អត់ ! កូនកើតបួសកើតអី គេមិនឱ្យមកផង តែថាកើតគេមិនឱ្យទៅផង។

កៈ ដឹងដំណឹងដែរតែគេអត់ឱ្យទៅ?

ខៈ ដឹងដែរតែគេអត់មានឱ្យយើងទៅនោះទេ។ ចាស!

កៈ ហ៊ឹស! ចាស!

ខៈ  គេឱ្យយើងជាន់អង្ករទៅ អាហ្នឹងយើងដូចថាគេផ្លាស់គ្នាណា។

កៈ ចាសៗ!

ខៈ  ឱ្យជាន់អង្កទៅរែកអង្កទៅបាយជ្រូកទៅសព្វគ្រាប់។

កៈ ចឹងយាយចេះតែបានដែរចឹងទៅហេសយាយ?

ខៈ ចេះតែទ្រាំទៅ ហើយដល់នេះទៅកាប់ព្រៃទៀតទៅ កាប់ព្រៃហ្នំទាល់តែព្រៃឈរហ្នំ។

កៈ ចាស! ចឹងក្រោកពីយប់ទៅចឹងឆ្ងាយសឹងអីណុង។

ខៈ ដេកនៅឯណុងគ្មានបានមកផ្ទះឯណា។

កៈ អូ!

ខៈ គ្មានឱ្យមកផ្ទះនោះទេ ហើយដល់ខ្មោចតាខ្ញុំហ្នឹង ក៏គេបំបែកកង៥ទៅឯហ្នំ នៅឯភ្នំជីហ្ន កាប់ឫស្សីហ្នំ គ្មានបានជួបគ្នានោះទេ បែកគ្នាទាំងអស់អ្នកងាប់អ្នកណារស់ក៏មិនដឹងដែរ។ ហាស!

កៈ បែកគ្នា

ខៈ ចឹងបានថាលំបាកណាស់ណា។

កៈ ហើយទៅ!

ខៈ រួចដាច់អាពតមករកអីស៊ីគ្មានទេ!

កៈ ពេលដាច់អាពតមក?

ខៈ បានអី មានតែរកព្រលឹតអីណុង។

កៈ យកមក?

ខៈ យកមកបុកធ្វើអង្ករណុងណា។

កៈ អូ!

ខៈ ធ្វើអង្កស៊ី។

កៈ ផ្លែព្រលិតហ្នឹងហ្អ៎?

ខៈ ផ្លែព្រលិតយើង។

កៈ ចាស! យកមក។

ខៈ បេះទាំងបេៗ ទាំងអស់គ្នា យកមកលាងទឹកទៅហាលទៅបុកទាំងអង្ករ ហើយបាយយើងវាមិនដូចជាបាយយើងសព្វថ្ងៃនេះនោះទេណា។

កៈ ចឹងធ្វើយ៉ាងម៉េចទៅ?

ខៈ វាបានជាចុងអង្កនោះទេណា។

កៈ ចាស! ដល់ពេលហាលរួចទៅយកមកដាំហើយវារីកទៅយាយ?

ខៈ អត់នោះទេ! ហាលរួច គេយកមកបុក។

កៈ ចឹង!

ខៈឡើងសស្គុះ

កៈ អូ! អាផ្កាៗវាហ្នឹងយាយហេស។

ខៈ ផ្កាវាផ្លែវាណុងណា ផ្លែព្រលិតណុងណា។

កៈ រួចទៅអកទៅមិនបាចដាំបាយទេ?

ខៈ ដាំបាយទៅ។

កៈ ហើយរួចទៅរីង?

ខៈ អត់មានរីងប៉ុន្មាននោះទេ វាដូចតែបាយយើងចឹងដែរ។

កៈ ឡើងរអួត

ខៈ ឡើងរអួតចឹងទៅហើសៗ។

កៈ ហ៊ឹម!

ខៈ កាលជំនាន់នោះសុតតែចឹង....

កៈ ហើយបន្តបន្ទាប់ទៀត

ខៈ ជូនកាលគេលាយចេក គេលាយអីទៅ។

កៈ ចាស! ហើយដល់ពេលក្រោយៗមកយាយមានជីវភាពធូរធារហ្នឹងប្រកបមុខរបរអ្វី?

ខៈ មិនទាន់បានធូរធារនោះទេ ហ្នឹងហើយ។

កៈ ចេះតែធ្វើមុខរបរអ្វីគេទៀតចឹង?

ខៈ មានធ្វើអីចេះតែធ្វើនេះនោះចឹងរកស៊ីបេះត្រកួនទៅ ស៊ីទៅណា កាលជំនាន់ណុងវាចឹង។

កៈ ចាស!

ខៈ ហើយដល់ពេលដីខ្ញុំ វាមិនតិចដែរ ដីគេចែកឱ្យហើយ។

កៈ ចឹង!

ខៈ ចាស!

កៈ ចឹងដីគេកាលណុង ជំនាន់ណុងងគេចែក?

ខៈ ជំនាន់ដាច់ណុងណា កាលជំនាន់ដាច់ណុងគេចែកអស់ទៅមានអីគេទៀត។

កៈ ចឹងដីកេរអាករខាង...

ខ៖ អស់ហើយ។

ក៖ គេយកអស់។

ខ៖ អស់ហើយ។

ក៖ គេដកហូតទៅ។

ខ៖ ដកហូតចែកគ្នាអស់ហើយ។

ក៖ អស់រលីង! ចាស!

ខ៖ ហើយរួចសួរទៅគ្រាន់តែថាខ្ញុំមិនសូវចេះនិយាយតែសួរចុះ។

ក៖ ហើយឥឡូវយាយដីរបបនុងគេចែកវិញដែរ?

ខ៖ គេចែកឱ្យដី៨មិតណុង។

ក៖ ក្បាល៨មិត បណ្តោយ?

ខ៖ បណ្តោយជិត១០០ដែរ។

ក៖ ហ៊ឹម! ចឹងបានអាហ្នឹងហើយយាយធ្វើស្រែ?

ខ៖ ហ្នឹងហើយបានអាហ្នឹង។

ក៖ ចាស!

ខ៖ រួចគ្នា៨នាក់គិតទៅ! ទាំងកូនទាំងចៅ ទាំងម្តាយខ្ញុំហ្នឹង គិតទៅវា៩នាក់ បើគិតទៅម្នាក់តែ៩មិតនោះទេ ហើយគិតមើល ដីយើងរាប់ហិចតាណា ស៊ីអី! បានអីស៊ី មើលវាមិនវេទនា! លំបាកជីវៈភាពរៀបរាប់ពីនុងមកវាវេទនាណាស់ រកបណ្តើរទឹកភ្នែកបណ្តើរណា។

កៈ ហ៊ឹម!

ខៈ ទម្រាំតែបានចិញ្ចឹមកូនរស់ទាល់តែឥឡូវហ្នឹង។

កៈ ចាស! មកដល់ពេលឥឡូវយាយបានធូរហើយនេសយាយ?

ខៈ  មកដល់ពេលឥឡូវបានកូនគេ  ពីលិចពីកើតមកទៅបន្តិចៗបន្តួចនោះមិនដឹងរកអីចេះតែហូប សព្វថ្ងៃដីនេះវាមិនបានធ្វើអីកើត។

កៈ ចឹង!

ខៈ សព្វថ្ងៃដៃខ្ញុំបាក់។

កៈ ចឹងយាយដួលហេសយាយ?

ខៈ ដួលម៉ូតូ ចៅឌុប

កៈ ហើយយាយឥឡូវយាយបានទៅវត្តហើយនេស?

ខៈ បានទៅវត្ត!

កៈ ចឹងនៅថ្ងៃសីលឡើងយាយទៅសុំសីលហ្នំយាយ?

ខៈ សុំសីលយូរឆ្នាំហើយ។

កៈ អូចឹងយាយចូលតាំងពីឆ្នាំណាចាំដេសយាយ?

ខៈ ចូលតាំងពីមើល តាំងពីការកាលខ្ញុំនៅម៉េច គិតទៅ១០ឆ្នាំហើយ។

កៈ ហាស! ខ្ញុំឃើញយាយទៅវត្តយូរដែរហើយ។

ខៈ ចាស! ជិត១០ឆ្នាំហើយ។

ក៖ ចាស! យាយនឹកឃើញថា មូលហេតុអ្វីបានយាយបានទៅចូលសុំសីលដោយសារអ្វី?

ខ៖ ដោយសារម៉េច ដោយសារអត់ពឹងកូនបាន យើងទូលខ្លួនយើងពឹងខ្លួនយើង។

ក៖ ចាស! ខ្លួនទីពឹងខ្លួនយើងណា។

ខ៖ គ្មានកូនណាមកជួយយើងបានទេ។ ចាស!

ក៖ ចាសៗ!

ខ៖ កូនជួយយើងមិនរួចនោះទេ យើងគ្រាន់អីបានព្រះពុទ្ធព្រះធម៌ព្រះសង្ឃជួយដែរ។

ក៖ ចាស! អូ!

ខ៖ ចាស!

ក៖ ហើយយ៉ាងម៉េចគេទៀតយាយ តើយាយមានបទពិសោធន៍អីដែលបានចងចាំមួយឆាកជីវិតយាយណា? ដូចថាមានការចងចាំអ្វីខ្លះសូមយាយបងស្រាយទៅមើល ដូចថាមានការលំបាកយ៉ាងម៉េច ហើយស្រណុកយ៉ាងម៉េចប្រកបមុខរបរអ្វី?

ខ៖ ការចងចាំនោះវាលំបាកគឺលំបាកទៅហើយ វាលំបាករហូតទៅហើយណា។

ក៖ ចាស!

ខ៖ហើយបានមករួចមក យើងវាបានផុតធ្វើនេះធ្វើនោះបន្តិចបន្តួចទៅ។

ក៖ ធ្វើអីគេនេះនោះបន្តិចបន្តួចធ្វើអី?

ខ៖ ធ្វើដូចថារកយើងដាំបន្លែយើងបន្តិចបន្តួចនៅស្រែស្រូវណុងទៅណា។

ក៖ ចាស!

ខ៖ ចាស!

ក៖ រួចពីធ្វើស្រែមកយើងបានទៅបន្តដាំបន្លែទៀតទៅ?

ខ៖ ដាំបន្តិចបន្តួចជីវភាពណុងទៀតទៅ គ្រាន់ចិញ្ចឹមជីវិតទៅ។

ក៖ ចាស!

ខ៖ ចាស!

ក៖ ចឹងឪឡូវនេះយាយអត់មានធ្វើចម្ការអីទៀតទេហ៎យាយ?

ខ៖ អត់ធ្វើទេ ឈប់ហើយ។

ក៖ ចឹងយាយរំពឹងថៅហើយនិងកូនអីជូនលុយអីចឹងហ៎យាយនេស?

ខ៖ ហ្នឹងហើយ ពឹងតែកូននឹងថៅហ្នឹងសព្វថ្ងៃហ្អ៎។

ក៖ ចឹងពិសារបាយអីជាមួយនឹងកូននោះទេហ្អ៎?

ខ៖ ជាមួយនឹងកូន។

ក៖ ចាស! ចឹងនៅជាមួយកូនរស់ហ្នឹង?

ខ៖ អត់ទេ នៅជាមួយកូនម្នាក់ទៀត តែគេអត់នៅគេទៅឯភ្នំពេញ។

ក៖ ចឹងកូនស្រី?

ខ៖ កូនស្រី

ក៖ តែគេទៅធ្វើការនៅភ្នំពេញហ្អ៎?

ខ៖ ចាស!

កៈ ធ្វើការខាងអីយាយ?

ខៈ ខាងលក់បន្លែហ្នឹង។

កៈ ហ៊ឹម! លក់បន្លែចឹងចំណាប់ណាស់នៅភ្នំពេញ។

ខៈ បានវាណុងហើយផ្តល់ឱ្យ។

កៈ ចឹងគាត់មានស្វាមីហើយនេសយាយ?

ខៈ មានហើយ។

កៈ ចុះអត់ទាន់មានកូន?

ខៈ អត់ទាន់មាន មិនមាននោះទេ ប្រហែលជាវាអស់ហើយអាយុជិត៥០ទៅហើយនោះហ្អ៎។

កៈ ចឹងអត់រហូត?

ខៈ អត់រហូតគ្មាននោះទេ។

កៈ ចឹងអត់ហើយចឹងហ្អ៎។

ខៈ ចាស!

កៈ ចាស!

ខៈ ហ្នឹងខ្ញុំថាប្រហែលជាកូនឯងជាតិមុនមក ប្រហែលជាកូនវាច្រើនហើយស្អប់កូនរញ៉េរញ៉ៃច្រើនពេកហើយបានជាចឹង។

កៈ អត់មានកូនជាតិហ្នឹង។

ខៈ ហាសៗ!

ក៖ អើយ!

ខ៖ សព្វថ្ងៃអាណិតដែរ ចឹងចាស់ទៅប្រាថ្នាចង់បានដែរ ក៏ប៉ុន្តែអត់មាន។

ក៖ សុំក្មួយណាមួយមកហាសៗ ចឹងយាយមុនហ្នឹងបញ្ចប់តើយាយមានពាក្យពេចន៍អ្វីដើម្បីផ្តាំផ្ញើរដល់កូនចៅ និង ប្អូនៗជំនាន់ក្រោយណា។

ខ៖ ចាស!

ក៖ តើមានពាក្យពេចន៍អ្វីដែរយាយ?

ខ៖ ផ្តែផ្តាំដែរ ផ្តែផ្តាំដូចថាកូនអើយខំរកទៅណា យើងចាស់ទៅយើងគ្មានអីទីពឹងនោះទេ ទីពឹងតែកម្លាំងដល់ពេលកម្លាំងយើងចាស់ទៅបានអីគេស៊ីខំរកទៅចាស់បានអីបន្តិចបន្តួចទៅ ចាស់ទៅគ្រាន់យើងបានរបស់ណុងគ្រាន់ទិញហូបទៅ។

ក៖ ចាស!

ខ៖ ចាសគ្រាប់កូនចឹង។

ក៖ ចាស!

ខ៖ ចាស! ផ្តែផ្តាំគ្រាប់កូនចឹងឱ្យកូនខំរកខំធ្វើអី ចាស់ទៅមិនដឹងត្រូវពឹងស្អីនោះទេ។

ក៖ ហ៊ឹមចាស! ចឹងខ្ញុំសូមអរគុណយាយច្រើន។

ខ៖ ចាស! សាធុ!

ក៖ ដែលបានខិតខំលះបង់ពេលវេលាឱ្យចៅធ្វើការសម្ភាសពីដំណើរជីវិតរបស់យាយ។

ខ៖ ចាសៗ!

ក៖  ចឹងខ្ញុំសូមថតរូបរបស់យាយ១ប៉ុស  និង  បទសម្ភាសហ្នឹងយកទៅដាក់នៅលើគេហទំព័ររបស់សាកលវិទ្យាល័យBYUនៅUSA តើយាយអនុញ្ញាតឱ្យចៅយកទៅដាក់ដែរ?

ខ៖ អត់អីទេ យកទៅដាក់ចុះ។

ក៖  ចាស!  ខ្ញុំសូមអរគុណយាយច្រើន  ខ្ញុំសូមជូនពរយាយឱ្យមានកម្លាំងមាំមួន  ភ្នែកយាយឱ្យនៅតែភ្លឺត្រចៀកយាយឱ្យនៅតែស្តាប់ឮណានិយាយកើត។

ខ៖ ចាស! សាធុ!

ក៖ ចាសៗ! ខ្ញុំសូមជម្រាបលាណាយាយ។

ខ៖ ចាស! ហើយក្មួយនោះក៏ឱ្យមានសេចក្តីសួរស្តីទៅណាកន្លែងណាកបនៅកន្លែងណុងណា។

ក៖ ចាស! សាធុៗយាយ។